# ចែករំលែកចំណេះដឹងនៃបទពិសោធន៍
# SHARE EXPERIENCE KNOWLEDGE

## ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន
**Positive Thinking Vs Negative Thinking**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ២៤ មេសា ២០១២

ចែករំលែកចំណេះដឹងដោយ (Knowledge shared by) : លោក សៀង ប៊ូហឿង

### ១. សេចក្តីផ្តើម (Introduction)

ជាបឋមខ្ញុំសូមធ្វើការពន្យល់និយមន័យនៃពាក្យ "ការគិតបែបវិជ្ជមាន" និង "ការគិតបែបអវិជ្ជមាន"។ ការគិតបែបវិជ្ជមាន ជាការយល់ឃើញថាល្អ ឬជាការមើលឃើញតែចំនុចល្អ។ រីឯការគិតបែបអវិជ្ជមាន ជាការយល់ឃើញមិនល្អ ឬជាការមើលឃើញតែចំនុចមិនល្អ។ ការគិតទាំងពីរបែបនេះមានលក្ខណៈផ្ទុយគ្នាស្រឡះ ប្រៀបដូចមេឃហើយនឹងដី ឆ្វេងហើយនឹងស្តាំ មុខហើយនឹងក្រោយ សត្រូវហើយនឹងសត្រូវ ឬទឹកហើយនឹងប្រេង។ ពេលខ្លះតម្រូវអោយយើងត្រូវតែធ្វើការគិតបែបវិជ្ជមាន ឬការគិតបែបអវិជ្ជមាន ឬទាំងពីរប្រភេទ។

### ២. ការយល់ដឹង (Knowledge)

ដើម្បីជាការងាយយល់ ខ្ញុំបាទសូមធ្វើអត្ថាធិប្បាយដោយលើកឡើងពីការគត់សំគាល់មួយចំនួនដូចខាងក្រោម :

| ស្ថានភាពកំពុងប្រឈម | ប្រភេទនៃការគិតដែលត្រូវប្រើ | មូលហេតុ ឬគោលបំណង |
|---|---|---|
| ការមិនសប្បាយចិត្ត ឬការតូចចិត្ត | ការគិតបែបវិជ្ជមាន | ដើម្បីជាការលើកទឹកចិត្ត |
| អារម្មណ៍រីករាយ ចូលចិត្ត និងគាំទ្រ | ការគិតបែបវិជ្ជមាន | ដើម្បីបំពេញចិត្តតាមអារម្មណ៍ |
| មានមោទនភាពក្នុងចិត្តខ្លាំងពេក | ការគិតបែបអវិជ្ជមាន | ដើម្បីបង្កើនការប្រុងប្រយ័ត្ន |
| អារម្មណ៍ស្អប់ មិនចូលចិត្ត ឬច្រណែន | ការគិតបែបអវិជ្ជមាន | ដើម្បីបំពេញចិត្តតាមអារម្មណ៍ |
| ការតាំងខ្លួនជាអាជ្ញាកណ្តាលដ៏ល្អ | ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន | ដើម្បីថ្លឹងថ្លែងរកយុត្តិធម៌ |
| ការវិភាគដើម្បីស្វែងយល់រកការពិត | ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន | ដើម្បីថ្លឹងថ្លែងរកការពិត |

ដូច្នេះការវិភាគដើម្បីស្វែងរកការពិត  គឺត្រូវប្រើនូវការគិតបែបវិជ្ជមាន  និងការគិតបែបអវិជ្ជមាន  ដើម្បីថ្លឹងថ្លែងរកការពិត ។ ខ្ញុំបាទសូមលើកឡើងពីការវិភាគក្រៅផ្លូវការណ៍ទាក់ទងខ្លះៗទៅនឹងគេហទំព័រ www.bigsek.org ដូចខាងក្រោមៈ

| | |
|---|---|
| ការបង្ហាញឈ្មោះ និងរូបថតរបស់អ្នកស្ថាបនិក នៅលើគេហទំព័រ | **ការគិតបែបវិជ្ជមាន**<br>ការធ្វើបែបនេះគឺជាការល្អ ដោយផ្តល់ភាពជឿជាក់ដល់អ្នកគាំទ្ររបស់ខ្លួន ហើយគេហទំព័រនេះនឹងមិនហ៊ានធ្វើអ្វីផ្តេសផ្តាសដែលផ្ទុយនឹងច្បាប់ទេ ។ |
| | **ការគិតបែបអវិជ្ជមាន**<br>ការធ្វើបែបនេះគឺគ្រាន់ជាការចង់ចេញមុខចេញមាត់ដើម្បីអោយល្បី និងដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនណាមួយតែប៉ុណ្ណោះ ។ |
| | **ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន**<br>ការធ្វើបែបនេះគឺជាការល្អ ដោយផ្តល់ភាពជឿជាក់ដល់អ្នកគាំទ្ររបស់ខ្លួន និងជាការធ្វើអោយខ្លួនល្បីឈ្មោះផងដែរ ។ |
| ការមិនបង្ហាញឈ្មោះ និងរូបថតរបស់អ្នកស្ថាបនិក នៅលើគេហទំព័រ | **ការគិតបែបវិជ្ជមាន**<br>ការធ្វើបែបនេះគឺជាការល្អ ដោយអ្នកស្ថាបនិក មិនចង់ចេញមុខចេញមាត់ ពិតជាមនុស្សល្អកម្រជួបមែន ។ |
| | **ការគិតបែបអវិជ្ជមាន**<br>ការធ្វើបែបនេះគឺជាការមិនល្អ ដោយសូម្បីតែឈ្មោះអ្នកណាជាអ្នកស្ថានិក ក៏មិនហ៊ានចេញមុខអោយគេដឹងផង អញ្ចឹងអោយទុកចិត្តយ៉ាងម៉េចទៅកើត ។ |
| | **ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន**<br>ការធ្វើបែបនេះ អាចដោយសារអ្នកស្ថាបនិក មិនចង់ចេញមុខចេញមាត់ ឬដោយសារមិនហ៊ានព្រោះខ្លួនអាចនឹងធ្វើទង្វើណាមួយដែលមិនសមរម្យ ។ |
|  | **ការគិតបែបវិជ្ជមាន**<br>រូបភាពនៃប្រអប់ដ៏ធំនេះ ពិតជាគួរអោយចាប់អារម្មណ៍ខ្លាំងណាស់ ដោយធ្វើអោយគេឆ្ងល់ និងចង់ដឹងថាតើមានអ្វីនៅខាងក្នុង ។ |
| | **ការគិតបែបអវិជ្ជមាន**<br>រូបភាពនៃប្រអប់ដ៏ធំនេះ ដូចជាក្តាម្ឈូសសម្រាប់ដាក់សាកសពអញ្ចឹង ។ |
| | **ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន**<br>រូបភាពនៃប្រអប់ដ៏ធំនេះ មើលយូរៗទៅ ពិតជាដូចក្តាម្ឈូសបន្តិចដែរ ។ នេះប្រៀបដូចជាឯកសារសម្រាប់ចែករំលែកទាំងនោះអញ្ចឹង គិតមួយភ្លែត ស្មានតែមិនបានការ តែតាមការពិត វាមានប្រយោជន៍ច្រើនណាស់ ។ |

| | |
|---|---|
| ឯកសារសម្រាប់ចែករំលែក អោយដោយមិនគិតលុយ | **ការគិតបែបវិជ្ជមាន**<br>ការធ្វើបែបនេះពិតជាសន្តានចិត្តដ៏ល្អ ហើយឯកសារសុទ្ធតែមានប្រយោជន៍ ។ |
| | **ការគិតបែបអវិជ្ជមាន**<br>នៅសុខៗ គេមិនដែលអោយយើងទទេទេ ប្រាកដជាមានគោលបំណងអ្វីមួយហើយ ។ ហើយឯកសារទាំងនោះប្រហែលយកពីគេមកដាក់ទាំងស្រុង ។ |
| | **ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន**<br>ការចែករំលែកបែបនេះ ជាសកម្មភាពដ៏ល្អ ហើយអាចដើម្បីគោលបំណងណាមួយ ។ ឯកសារអាចមានស្រាប់ ឬអាចបង្កើតថ្មីដោយខ្លួនឯង ។ |
| ឯកសារសម្រាប់ចែករំលែក អោយដោយគិតលុយ និងបង់តាមប្រព័ន្ធធនាគារលើអ៊ីនធឺណេត | **ការគិតបែបវិជ្ជមាន**<br>ជាធម្មតាទេ គេត្រូវការលុយខ្លះហើយដើម្បីអាចទ្រទ្រង់អង្គភាពរបស់គេ ។ |
| | **ការគិតបែបអវិជ្ជមាន**<br>គ្រាន់តែអញ្ចឹង ក៏គិតលុយដែរ គ្មានចិត្តធ្វើបុណ្យក្នុងការចែករំលែកសោះ ។ |
| | **ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន**<br>វាត្រូវហើយបើមិនយកលុយ ធ្វើម៉េចអាចបន្តការងារនេះជានិរន្តតទៅទៀត តែវាហាក់ដូចជាមានចិត្តមិនសូវទូលាយទេ ។ |
| ការចុច"Like" ដោយប្រើប្រាស់ Facebook ដើម្បីជាការគាំទ្រ | **ការគិតបែបវិជ្ជមាន**<br>មានអីពិបាក គ្រាន់តែចុច"Like" ដើម្បីជាការគាំទ្រ ។ ល្អណាស់! |
| | **ការគិតបែបអវិជ្ជមាន**<br>ចុចផ្ដេសផ្ដាស់យ៉ាងម៉េចកើត មិនស្រួលអាចជាប់គុកជាប់ច្រវាក់ទៀត ។ |
| | **ការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន**<br>គ្រាន់តែចុច"Like" ដើម្បីជាការគាំទ្រ មានទៅស៊ី ។ ហើយបើគេហទំព័រនោះ ធ្វើអ្វីផ្ដេសផ្ដាសខុសច្បាប់ ក៏មិនពាក់ព័ន្ធខ្ញុំដែរ ។ រូបស៊ិចស៊ីមួយចំនួនចុច"Like" គាំទ្ររាប់ពាន់អ្នក មិនទៅស៊ីផង ។ ពេលមានបញ្ហា ជាប់គុកអាអ្នកបង្ហោះឯណោះ មិនមែនអ្នកចុច"Like" ទេ ។ |

### ៣. ការផ្ដល់អនុសាសន៍ (Recommendation)

ខ្ញុំបាទសូមធ្វើការផ្ដល់ជាគំនិតយោបល់យ៉ាងខ្លីថា ដើម្បីទទួលបានលទ្ធផល ក៏ដូចជាភាពជោគជ័យក្នុងការវិភាគរកការពិត គឺយើងត្រូវប្រើប្រាស់ទាំងការគិតបែបវិជ្ជមាន និងការគិតបែបអវិជ្ជមាន ដោយយកវាមកថ្លឹងថ្លែង ។ ស្រដៀងគ្នាផងដែរ "ចែករំលែកចំណេះដឹងនៃបទពិសោធន៍" តាមរយៈសកម្មភាពនៃការចែករំលែក នឹងដើរតួនាទីប្រៀបដូចជាជញ្ជីង ដោយឈរនៅត្រង់ចំនុចកណ្ដាលក្នុងការវិភាគរកការពិត ។

មកដល់ពេលនេះ ក៏មានទស្សនៈយល់ឃើញខុសៗគ្នាចំពោះគេហទំព័រ [www.bigsek.org](http://www.bigsek.org) ផងដែរ ។ ទោះបីជាមើលឃើញថាទទួលបានការគិតបែបវិជ្ជមាន ច្រើនជាងការគិតបែបអវិជ្ជមានក៏ដោយ ក៏គេហទំព័រ [www.bigsek.org](http://www.bigsek.org) នៅតែប្រកាន់ជំហរកណ្តាលដើម្បីទទួលបានជោគជ័យ ។ អត្ថន័យមានដូចក្នុងរូបវិភាគកំសាន្តខាងក្រោម៖




